**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

ថ្ងៃសុក្រ ១៤កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៨

លេខ: ២៥១ កបទ.សអ.បល

# សេចក្តីជូនដំណឹង

សូមជូនដំណឹងដល់សាធារណជនឲ្យបានជ្រាបថា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីក្របខណ្ឌ "ក" ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ សៅរ៍ ៨រោច ឆ្នាំច ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១៨ សម្រាប់ឆ្នាំ ២០១៨ ចំនួន ១៤ នាក់ លើមុខជំនាញដូចខាងក្រោម៖

- ភាសាអង់គ្លេស ចំនួន ០៩ នាក់
- ភាសាបារាំង ចំនួន ០២ នាក់
- ភាសាកូរ៉េ ចំនួន ០១ នាក់
- ភាសាជប៉ុន ចំនួន ០១ នាក់
- ភាសាវៀតណាម ចំនួន ០១ នាក់

បេក្ខជន-បេក្ខនារី ត្រូវមានលក្ខណៈសម្បត្តិដូចតទៅ៖

១. មានសញ្ញាបត្រចាប់ពី**បរិញ្ញាបត្រ**ឡើងលើមុខជំនាញ៖ ភាសាអង់គ្លេស(កម្រិត IELTS 5.5 ឡើង) ភាសាបារាំង ភាសាកូរ៉េ ភាសាជប៉ុន ភាសាវៀតណាម ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ សេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងគណនេយ្យ។

២. មានសញ្ជាតិខ្មែរ និងសុខភាពល្អ

៣. អាយុ៖
- មិនលើស ៣៥ឆ្នាំ សម្រាប់សញ្ញាបត្របរិញ្ញាបត្រ (គិតត្រឹមថ្ងៃប្រឡង)
- មិនលើស ៤០ឆ្នាំ សម្រាប់សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ (គិតត្រឹមថ្ងៃប្រឡង)
- មិនកំណត់អាយុសម្រាប់សញ្ញាបត្រថ្នាក់បណ្ឌិត

៤. ជនពិការ ដែលមានសមត្ថភាពសមស្រប និងបេក្ខនារី ត្រូវបានលើកទឹកចិត្ត ។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

បញ្ជាក់ ៖ - សញ្ញាបត្រពីក្រៅប្រទេស ត្រូវបញ្ជាក់ពីនាយកដ្ឋានឧត្តមសិក្សា

- សញ្ញាបត្រក្នុងប្រទេស ត្រូវបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន
- បេក្ខជន-នារី ត្រូវបំពេញសំណុំបែបបទ៖ ពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសមន្ត្រី ចំនួន ០១ ច្បាប់ ជីវប្រវត្តិសង្ខេប ចំនួន ០១ ច្បាប់ សលាកប័ត្រឯកត្តជន ០១ ច្បាប់ និងបង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង ចំនួន ០១ ច្បាប់
- ត្រូវបញ្ជាក់អំពីភាពគ្មានទោស (លិខិតថ្កោលទោស) ពីក្រសួងយុត្តិធម៌ និងលិខិតបញ្ជាក់អំពីសុខភាពពីមន្ទីរពេទ្យរដ្ឋបន្ទាប់ពីបេក្ខជន-បេក្ខនារី ប្រឡងជាប់ជាស្ថាបពរ
- ការដាក់ពាក្យប្រឡងតម្រូវឲ្យបង់ប្រាក់ចំនួន ២០.០០០ រៀល ។

វិញ្ញាសាប្រឡង ៖

វិញ្ញាសាសរសេរ និងវិញ្ញាសាសួរផ្ទាល់មាត់៖ ភាសាអង់គ្លេស បារាំង ជប៉ុន កូរ៉េ ឬ វៀតណាម ។

សាធារណជន ដែលមានបំណងចូលរួមប្រឡង សូមទាញយក និងបំពេញសំណុំបែបបទសុំសិទ្ធិប្រឡង តាមរយៈគេហទំព័រក្រសួង www.mfaic.gov.kh និងទំព័រហ្វេសប៊ុកក្រសួង www.facebook.com/mfaic.gov.kh។

ការទទួលពាក្យ នឹងត្រូវចាប់ផ្តើមពីថ្ងៃ**ផ្សាយដំណឹងនេះ** រហូតដល់ថ្ងៃ**ចន្ទ ៧កើត ឆ្នាំច ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៨** រៀងរាល់ម៉ោងធ្វើការ នៅនាយកដ្ឋានបុគ្គលិក នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលមានអាសយដ្ឋានអគារលេខ ៣ វិថី **សម្តេច ហ៊ុន សែន** សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ។

បញ្ជាក់៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានសិទ្ធិជម្រុះបេក្ខជន-បេក្ខនារី ដែលមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ មិនអោយចូលរួមប្រឡង។

**ប្រធានគណៈកម្មការរៀបចំការប្រឡង**

**ប្រាក់ សុខុន**

ចម្លងជូន:
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# បទបញ្ញត្តិទូទៅ
## សម្រាប់បេក្ខជន-បេក្ខនារី ប្រឡងប្រជែងចូលបម្រើការងារជាមន្ត្រីក្របខណ្ឌថ្មី ១៤ នាក់ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
## នៅថ្ងៃ សៅរ៍ ៨រោច ឆ្នាំច ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១៨

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និងវិន័យ បេក្ខជន-បេក្ខនារី ចូលរួមប្រឡងប្រជែងជ្រើសរើសមន្ត្រីក្របខណ្ឌថ្មីឆ្នាំ ២០១៨ ត្រូវគោរពបទបញ្ញត្តិទូទៅ ដូចខាងក្រោម ៖

ការប្រឡងវិញ្ញាសាសរសេរនិងសួរផ្ទាល់មាត់ ចាប់ផ្តើមនៅម៉ោង ០៨៖៣០នាទី

ក. បេក្ខជន-បេក្ខនារី ត្រូវ ៖

១. មកដល់មណ្ឌលប្រឡងយ៉ាងតិច ៣០នាទី មុនពេលដំណើរការនៃការប្រឡង
២. យកមកជាមួយនូវបង្កាន់ដៃប្រឡង
៣. អង្គុយតាមលេខតុដែលបានកំណត់ដោយគណៈកម្មការប្រឡង
៤. ឲ្យមន្ត្រីអនុរក្សឆែក និងដកហូតឯកសារដែលក្រសួងមិនអនុញ្ញាតឲ្យយកចូលក្នុងបន្ទប់ប្រឡង
៥. ប្រគល់សន្លឹកកិច្ចការឲ្យមន្ត្រីអនុរក្សនៅពេលបញ្ចប់ម៉ោងប្រឡង ទោះបីកិច្ចការនោះធ្វើពុំទាន់ចប់ក៏ដោយ។

ខ. ហាម ៖

១. ចូលក្នុងបន្ទប់ប្រឡងមុនពេលមន្ត្រីអនុរក្សហៅឈ្មោះ
២. ស្លៀកពាក់ឯកសណ្ឋានកងកម្លាំងប្រដាប់អាវុធ និងសម្លៀកបំពាក់មិនសមរម្យចូលក្នុងបន្ទប់ប្រឡង
៣. ហាមយកទូរស័ព្ទដៃ ចូលក្នុងបន្ទប់ប្រឡង
៤. យកអាវុធជាតិផ្ទុះចូលក្នុងបន្ទប់ប្រឡង
៥. ប្រើពាក្យសំដី ឬអាកប្បកិរិយាមិនសមរម្យទៅលើគណៈមេប្រយោគ និងមន្ត្រីអនុរក្សនៅក្នុងបន្ទប់ប្រឡង

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

៦. សរសេរចម្លើយវិញ្ញាសានៅលើក្រដាសកិច្ចការ ដែលគ្មានហត្ថលេខារបស់មន្ត្រីអនុរក្ស
៧. ចម្លងសំណួរវិញ្ញាសាចូលក្នុងក្រដាសកិច្ចការផ្សេង ឬបោះសំណួរវិញ្ញាសាចេញក្រៅបន្ទប់ប្រឡង
៨. ងើបឈរ ងាកឆ្វេង-ស្តាំ ឬដើរចេញពីកន្លែងប្រឡងដោយគ្មានការអនុញ្ញាតពីមន្ត្រីអនុរក្ស
៩. ឡូឡា ឬទាញយកក្រដាសកិច្ចការរបស់អ្នកដទៃមកចម្លង
១០. ប្តូរគ្នានូវក្រដាសកិច្ចការ ក្រដាសព្រាង ផ្ទៀងផ្ទាត់ចម្លើយ ឬចម្លងគ្នា និងដាក់ក្រដាសកិច្ចការឆ្ងាយពីមុខរបស់ខ្លួន ដើម្បីឲ្យអ្នកដទៃមើល ឬទាញយកបានឡើយ
១១. សរសេរប៊ិចពណ៌ផ្សេងក្រៅពីប៊ិចពណ៌ខៀវដែលចែកជូននៅលើក្រដាសកិច្ចការ និងធ្វើសញ្ញាសម្គាល់លើក្រដាសកិច្ចការរបស់ខ្លួន ដូចជា៖ ការសរសេរអក្សរប្លែកពីតួអក្សរទាំងអស់ក្នុងកិច្ចការ ធ្វើសញ្ញាផ្សេងៗ ឬគូរបន្ទាត់ខុសប្រក្រតី
១២. លាក់ ឬហែកក្រដាសកិច្ចការរបស់ខ្លួន និងហែក ឬលាក់ក្រដាសកិច្ចការអ្នកដទៃ
១៣. ធ្វើឲ្យខូចខាតឬបាក់បែកសម្ភារៈនៅក្នុងបន្ទប់ប្រឡង
១៤. អ្នកដទៃប្រឡងជំនួស ឬសរសេរបំពេញបន្ថែមលើក្រដាសកិច្ចការរបស់ខ្លួនជាដាច់ខាត
១៥. បង្កសកម្មភាព ដែលនាំឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយ នៃការប្រឡង។

ក្នុងករណីបេក្ខជន-បេក្ខនារីណាម្នាក់ បំពានចំណុចណាមួយដូចដែលមានចែងក្នុងបទបញ្ញត្តិខាងលើ គណៈកម្មការរៀបចំការប្រឡងមានសិទ្ធអោយបេក្ខជន-បេក្ខនារីបោះបង់ការប្រឡង។

ថ្ងៃសុក្រ ១៤កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៨
**ប្រធានគណៈកម្មការរៀបចំការប្រឡង**

**ប្រាក់ សុខុន**